ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...

អនុក្រឹត្យ

ស្តីពី

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាចារឹក:

របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រួច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់ការគោរពវិន័យការងារ និងបង្កើនប្រសិទ្ធភាពការងាររបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២.-

អនុក្រឹត្យនេះ មានគោលដៅកំណត់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា៥៨ កថាខណ្ឌ៤ នៃច្បាប់ស្តីពីគយ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧។

មាត្រា៣.-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្ត ចំពោះមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី២

ឯកសណ្ឋាន

មាត្រា៤.-

ឯកសណ្ឋាន នៃមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជារួមមាន ម្ជុក អាវ ខោ ឬសំពត់ពណ៌ត្រាវចាស់ ក្រវាត់កពណ៌ខៀវ ខ្សែក្រវាត់ ស្រោមជើង និងស្បែកជើងឃ្លុបកខ្លីពណ៌ត្នោត។ មន្ត្រីរាជការដែលជានារី អាចស្លៀកសំពត់ហ្ស៊ីបឆែកក្រោយ មានសម្រុងក្រោមជង្គង់ ស្បែកជើងកែងមានក្រវាត់កម្ពស់មិនលើសពី ៥០(ហាសិប) មីលីម៉ែត្រ។

មាត្រា៥.-

ឯកសណ្ឋាន នៃមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ចែកចេញជា ០៣ ប្រភេទ ដូចខាងក្រោម÷

១. ឯកសណ្ឋានការងារ

២. ឯកសណ្ឋានប្រជុំ

៣. ឯកសណ្ឋានពិធីការ។

មាត្រា៦.-

ឯកសណ្ឋានការងារ ត្រូវបានកំណត់ ដូចខាងក្រោម÷

- អាវសីមីដៃខ្លី បើកក មានហោប៉ៅលើពីរ មានគម្របរាងស្លីកពោធិ៍ មានឡេវ និងបន្ទះខ្សែស្មា។ នៅខ្នងអាវខាងក្រោយមានជីបស្មាសងខាង ចុងដៃបត់ចូលក្នុង ដេរថ្នេរនុប។ ដើមដៃអាវស្តាំមានដេរភ្ជាប់រូបចង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា រាងជារង្វង់មានអង្កត់ផ្ចិតហុកសិបប្រាំមីលីម៉ែត្រ នៅផ្នែកខាងលើផ្នែកពណ៌ខៀវមានចារឹកអក្សរមូលថា "**ព្រះរាជាណាចក្រកម្ពុជា**" រាងកោង។ លើផ្នែកពណ៌ខៀវក្រោមរូបប្រាសាទកំពូលបីមានចារឹកអក្សរមូលថា "**គយ និង រដ្ឋាករ**" ផ្តេកត្រង់។ នៅខាងក្រោមអក្សរ "**គយ និង រដ្ឋាករ**" មានចារឹកអក្សរមូលថា "**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**" រាងកោង។
- អាវត្រូវសិកក្នុងខោ ឬសំពត់ ក្រវាត់ខ្សែក្រវាត់។

- ខោជើងវែង ចង្កេះដេរតថ្នេរបង្កប់ ជីបភ្លីខាងមុខមួងពីរ មានហោប៉ៅបួន ហោប៉ៅពីរខាងក្រោយដេរបង្កប់ មានគម្របរាងស្លឹកពោធិ៍មានឡេវ និងហោប៉ៅចំហៀងសងខាងដេរបង្កប់តាមថ្នេរខោ ។
- អ្នកកេពី ឬអ្នកហ្សកកី មានក្បាំងមុខរឹង ស្រោបដោយសំពត់កម្ទីពណ៌ខៀវ និងមានក្បូរក្បាច់រចនាតាមឋានៈនៅផ្នែកខាងមុខ។ អ្នកកេពីផ្នែកខាងក្រោយ មានព័ទ្ធវ៉ែលសំពត់កម្ទីពណ៌ទឹកបិច។

ឯកសណ្ឋានការងារ មានគំរូ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ១/៥៤, ២/៥៤, ៣/៥៤ និង ៤/៥៤ នៃអនុក្រឹត្យនេះ។

មាត្រា៧.-

ឯកសណ្ឋានការងារ ត្រូវប្រើប្រាស់សម្រាប់បំពេញការងារប្រចាំថ្ងៃរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

មាត្រា៨.-

ឯកសណ្ឋានប្រជុំ ឬ "សាហារីយ៉ែន" ត្រូវបានកំណត់ ដូចខាងក្រោម÷

- អាវដៃខ្លី បើកក មានហោប៉ៅបួន ហោប៉ៅពីរលើមានគម្របរាងស្លឹកពោធិ៍និងហោប៉ៅពីរក្រោមមានគម្របត្រង់ មានឡេវនិងបន្ទះខ្សែស្មា។ ផ្នែកខាងខ្នងមានជីបសងខាងបត់ត្រង់ចុះក្រោមរហូតដល់ជាយអាវមានថ្នេរសង្កត់ពីត្រង់ចង្កេះសងខាងបត់ចុងដៃចូលក្នុង ដេរថ្នេរឆុប។ ដើមដៃអាវស្តាំមានដេរភ្ជាប់រូបទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជាវាងជារង្វង់មានអង្កត់ផ្ចិតហុកសិបប្រាំមីល្លីម៉ែត្រ នៅផ្នែកខាងលើផ្នែពណ៌ខៀវមានចារឹកអក្សរមូលថា "**ព្រះរាជាណាចក្រកម្ពុជា**" រាងកោង។ លើផ្នែពណ៌ខៀវក្រោមរូបប្រាសាទកំពូលបីមានចារឹកអក្សរមូលថា "**គយ និង រដ្ឋាករ**" ផ្តេកត្រង់។ នៅខាងក្រោមអក្សរ "**គយ និង រដ្ឋាករ**" មានចារឹកអក្សរមូលថា "**ជ័យសូច សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**" រាងកោង។
- អ្នកកេពី ខោឬសំពត់ ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើង ដូចប្រើជាមួយឯកសណ្ឋានការងារ។

ឯកសណ្ឋានប្រជុំ មានគំរូ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ៤/៥៤, ៥/៥៤ និង ៦/៥៤ នៃអនុក្រឹត្យនេះ។

មាត្រា៩.-

ឯកសណ្ឋានប្រជុំ ត្រូវប្រើប្រាស់សម្រាប់ពិធីប្រជុំការងារ ពិធីមិទ្ធិញ អង្គសិក្ខាសាលា ការទទួលភ្ញៀវ និងពេលធ្វើទស្សនកិច្ចនានា។

មាត្រា១០.-

ឯកសណ្ឋានពិធីការ ត្រូវបានកំណត់ ដូចខាងក្រោម÷

- អាវភ្ញីមានឆែកខាងក្រោយ កបើក ដៃវែង និងបន្ទះខ្សែស្មា មានហោប៉ៅបួនដេរប៉ះ ហោប៉ៅពីរលើមានគម្រប រាងស្លឹកពោធិ៍ ហោប៉ៅពីរក្រោមមានគម្របត្រង់មានឡេវរូបព្រះសង្ខារ។ អាវនេះមានឡេវរូបព្រះសង្ខារចំនួន ៤គ្រាប់។ ដៃអាវរាងបំពង់បកចុងដៃអាវមកក្រៅប្រវែងប៉ែតសិបប្រាំមីល្លីម៉ែត្រ នៅចុងដៃអាវនីមួយៗមានឡេវបណ្តោតរូបព្រះសង្ខារចំនួនបីគ្រាប់។ នៅក្នុងអាវភ្ញីមានពាក់អាវសដៃវែង បិទឡេវដៃ និងមានក្រវាត់កពណ៌ខៀវ។
- ឡេវអាវរូបព្រះសង្ខារពណ៌មាសប្រើសម្រាប់មន្ត្រីរាជការគយនិងរដ្ឋាករដែលមានឋានៈជាអគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន ប្រធានលេខាធិការដ្ឋាន អនុប្រធាននាយកដ្ឋាន អនុប្រធានលេខាធិការដ្ឋាន និងប្រធានសាខាគយនិងរដ្ឋាករ។ ឡេវអាវរូបព្រះសង្ខារពណ៌ប្រាក់ប្រើសម្រាប់មន្ត្រីរាជការគយនិងរដ្ឋាករ មានឋានៈជាប្រធានការិយាល័យចុះ។

- ម្ហូកកេពី ខោឬសំពត់ ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើង ដូចប្រើជាមួយឯកសណ្ឋានការងារ។

ឯកសណ្ឋានពិធីការ មានគំរូដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ៧/៥៤, ៨/៥៤ និង ៩/៥៤ នៃអនុក្រឹត្យនេះ។

មាត្រា១១.-

ឯកសណ្ឋានពិធីការ ត្រូវបានប្រើសម្រាប់ពិធី ដូចខាងក្រោម÷

- ព្រះរាជពិធី
- ពិធីបុណ្យជាតិធំៗ
- ពិធីប្រជុំធំៗ
- ពិធីទទួលភ្ញៀវអន្តរជាតិជាន់ខ្ពស់
- ពិធីទស្សនកិច្ចផ្លូវការនៅក្រៅប្រទេស។

មាត្រា១២.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចកំណត់បន្ថែមដោយប្រកាស នូវឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈ តាមស្ថានភាពទីកន្លែង ប្រភេទនៃប្រតិបត្តិការគយ និងរដូវកាល ដើម្បីធានាសុខដុមនីយកម្មការងារគយនិងរដ្ឋាករ។

ជំពូកទី៣

សញ្ញាសម្គាល់

មាត្រា១៣.-

សញ្ញាសោដាក់បញ្ឈរខ្វែងជាមួយយុថ្កាលើស្លាបសត្វត្រដាងតំណាងឱ្យច្រកចេញចូលផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ទំហំពីចុងស្លាបម្ខាងដល់ចុងស្លាបម្ខាងប្រវែងសែសិបមួយមីល្លីម៉ែត្រ (៤១ ម.ម) និងកម្ពស់ម្ភៃបីមីល្លីម៉ែត្រ (២៣ ម.ម) ត្រូវបានប្រើសម្រាប់ខ្ទាស់នៅលើ កអាវសងខាង។

មាត្រា១៤.-

សញ្ញាកងចក្រមានអង្កត់ផ្ចិតហុកសិបមួយមីល្លីម៉ែត្រ (៦១ ម.ម) មានធ្មេញកងចក្រចំនួនប្រាំបួន តំណាងថ្ងៃទទួលបានឯករាជ្យ។ នៅលើកងចក្រមានចំណុចមូលក្រឡោតដាក់តំរៀបជារង្វង់ចំនួនហាសិបបី តំណាងឆ្នាំទទួលបានឯករាជ្យ។ ខាងក្នុងកងចក្រផ្នែកខាងលើ មានចារឹកអក្សរមួលថា "**ព្រះរាជាណាចក្រកម្ពុជា**" រាងកោង។ ចំកណ្តាល មានរូបប្រាសាទកំពូលបី។ ក្រោមប្រាសាទកំពូលបី មានចារឹកអក្សរមួលថា "**គយ និង រដ្ឋាករ**"។ នៅខាងក្រោមអក្សរ "**គយ និង រដ្ឋាករ**" មានចារឹកអក្សរមួលថា "**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**" រាងកោង។ សញ្ញាកងចក្រ ត្រូវបានប្រើសម្រាប់ខ្ទាស់នៅចំពាក់កណ្តាលហោប៉ៅអាវលើផ្នែកខាងស្តាំ។

មាត្រា១៥.-

ស្លាកឈ្មោះរាងបួនជ្រុងទ្រវែងបណ្តោយកៅសិបមួយមីល្លីម៉ែត្រ (៩១ ម.ម) ទទឹងម្ភៃប្រាំមីល្លីម៉ែត្រ (២៥ ម.ម) ផ្នែកខាងឆ្វេងដៃ មានរូបសញ្ញាកងចក្រគយ។ ផ្នែកខាងស្តាំដៃ ខាងលើសម្រាប់សរសេរឈ្មោះមន្ត្រីរាជការគយនិងរដ្ឋាករ ផ្នែកកណ្តាលសរសេរជាភាសាអង់គ្លេសថា "CUSTOMS AND EXCISE" ខាងក្រោមសរសេរជាអក្សរឡាតាំង ID និងអត្តលេខរបស់មន្ត្រីរាជការគយនិងរដ្ឋាករ។

មាត្រា១៦.-

ក្បាលខ្សែក្រវាត់ធ្វើពីលោហធាតុរាងបួនជ្រុងទ្រវែង ចំកណ្តាលផ្នែកខាងលើចារឹកអក្សរមួលថា "**គយ និង រដ្ឋាករ**" ផ្នែកខាងក្រោមចារឹកអក្សរជាភាសាអង់គ្លេសថា "CUSTOMS AND EXCISE"។

មាត្រា១៧.-

សញ្ញាសម្គាល់ពណ៌មាស ត្រូវបានប្រើប្រាស់សម្រាប់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន ប្រធានលេខាធិការដ្ឋាន អនុប្រធាននាយកដ្ឋាន អនុប្រធានលេខាធិការដ្ឋាន និងប្រធានសាខាគយនិងរដ្ឋាករ ដូចមានគំរូក្នុងឧបសម្ព័ន្ធ ១០/៥៤, ១១/៥៤, ១២/៥៤ និង ១៣/៥៤ នៃអនុក្រឹត្យនេះ។

សញ្ញាសម្គាល់ពណ៌ប្រាក់ ត្រូវបានប្រើប្រាស់សម្រាប់ប្រធានការិយាល័យចុះ ដូចមានគំរូក្នុងឧបសម្ព័ន្ធ ១៤/៥៤, ១៥/៥៤, ១៦/៥៤, ១៧/៥៤ និង ១៨/៥៤ នៃអនុក្រឹត្យនេះ។

ជំពូកទី៤

សញ្ញាឋានៈ

មាត្រា១៨.-

សញ្ញាឋានៈ ត្រូវបានកំណត់តាមឋានានុក្រមមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដូចខាងក្រោម÷

១. ថ្នាក់អគ្គនាយក

២. ថ្នាក់អគ្គនាយករង

៣. ថ្នាក់ប្រធាននាយកដ្ឋាន និងប្រធានលេខាធិការដ្ឋាន

៤. ថ្នាក់អនុប្រធាននាយកដ្ឋាន អនុប្រធានលេខាធិការដ្ឋាន និងប្រធានសាខាគយនិងរដ្ឋាករ

៥. ថ្នាក់ប្រធានការិយាល័យ ជំនួយការនាយកដ្ឋាន អនុប្រធានសាខា និងប្រធានស្ថីទីសាខាគយនិងរដ្ឋាករ

៦. ថ្នាក់អនុប្រធានការិយាល័យ ជំនួយការសាខា និងប្រធានស្ថីទីការិយាល័យគយនិងរដ្ឋាករ

៧. ថ្នាក់ភ្នាក់ងារគយនិងរដ្ឋាករ។

មាត្រា១៩.-

សញ្ញាឋានៈ សម្រាប់ភ្នាក់ងារគយនិងរដ្ឋាករ ត្រូវបានកំណត់ តាមអតីតភាពការងារ ដូចខាងក្រោម÷

១. ថ្នាក់កម្មសិក្សាការី ជាភ្នាក់ងារគយនិងរដ្ឋាករដែលបានប្រឡងជាប់ជាស្ថាពរ បានសិក្សាចប់ជំនាញបច្ចេកទេសគយនិងរដ្ឋាករបឋម និងស្ថិតក្នុងកម្មសិក្សា រហូតដល់ថ្ងៃតាំងស៊ប់

២. ថ្នាក់ភ្នាក់ងារគយនិងរដ្ឋាករបឋម ជាភ្នាក់ងារគយនិងរដ្ឋាករដែលបានបំពេញការងារពីថ្ងៃតាំងស៊ប់ រហូតដល់ ៥ឆ្នាំ

៣. ថ្នាក់ភ្នាក់ងារគយនិងរដ្ឋាករដើមខ្សែ ជាភ្នាក់ងារគយនិងរដ្ឋាករដែលបានបំពេញការងារពី ៦ឆ្នាំ ដល់ ១០ឆ្នាំ

៤. ថ្នាក់ភ្នាក់ងារគយនិងរដ្ឋាករដើមខ្សែពិសេស ជាភ្នាក់ងារគយនិងរដ្ឋាករដែលបានបំពេញការងារពី ១១ឆ្នាំ ដល់ ២០ឆ្នាំ

៥. ថ្នាក់ភ្នាក់ងារគយនិងរដ្ឋាករដើមខ្សែជុតថ្នាក់ ជាភ្នាក់ងារគយនិងរដ្ឋាករដែលបានបំពេញការងារពី ២១ឆ្នាំឡើង។

មាត្រា២០.-

សញ្ញាឋានៈអគ្គនាយក ត្រូវបានកំណត់ ដូចខាងក្រោម ÷

១. មួកកេពីនិងហ្សីកកឺ÷

នៅផ្នែកខាងលើមុខមួកមានរូបព្រះសង្ខារពណ៌មាស ជាយក្បាំងខាងលើ មានក្បាច់រចនាផ្កាឈូកបីទងពណ៌មាសនៅចំកណ្តាល និងអមដោយក្បាច់ភ្ញីទេសនៅសងខាង។ ចំកណ្តាលក្បាំង មានខ្សែវ័ណ្ឌក្រឡាក្តែបពណ៌មាសពីលើ ហើយចុងសងខាងនៃខ្សែក្រឡាក្តែបនេះមានលម្ហដោយឡេវ្រែរូបព្រះសង្ខារពណ៌មាសមួយ។ ជាយក្បាំងខាងមុខ មានក្បាច់

ផ្កាឈូកបីស្រទាប់ពណ៌មាសនៅចំកណ្តាល បន្ទាប់មកមានក្បាច់ក្រួស្រូវនិងក្បាច់សន្លឹកភ្ញីទេសនៅអមសងខាង ពណ៌មាស។ ជាយក្បាំងខាងមុខមួក មានក្បាច់ផ្កាដួងពណ៌មាសព័ទ្ធពីចុងម្ខាងទៅចុងម្ខាង។

២. សក្តិស្មា÷

សក្តិស្មាមានផ្នែកម្ជីពណ៌ខៀវ តុបតែងរចនាដោយក្បាច់ភ្ញីទេសនិងភ្ញីវល្លិ៍ព័ទ្ធជុំវិញ ចំកណ្តាលផ្នែកក្រោម មានចារឹកអក្សរមួល "**គយ ឆិទ ឈ្លោករ**" លើបន្ទះលោហៈពណ៌មាសរាងបួនជ្រុងទ្រវែង ខាងលើបន្ទះលោហៈនេះ មានកងចក្រគយពណ៌មាសចំនួនបួន តំរៀបគ្នាជារាងចតុកោណស្មើ ខាងលើកងចក្របួននេះ មានរូបព្រះខ័នឥតស្រោមពីរដាក់បញ្ឈរខ្វែងគ្នាពណ៌មាសទ្រមកុដរាជ្យពណ៌មាស។ លើកំពូលមកុដរាជ្យ មានកាំរស្មីរាងជារង្វង់ពណ៌មាស ខាងលើកាំរស្មី មានឡេវរួបព្រះសង្ខារពណ៌មាសសម្រាប់សក្តិស្មា មានចុងស្រួចពាក់ជាមួយឯកសណ្ឋានប្រជុំឬសាហាវីយ៉ែន និងឯកសណ្ឋានពិធីការ។ សក្តិប្រើជាមួយឯកសណ្ឋានការងារ ខាងចុងកាត់ស្មើគ្មានឡេវរួបព្រះសង្ខារពណ៌មាសទេ។

សញ្ញាឋានៈអគ្គនាយក មានគំរូ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ១៩/៥៤, ២០/៥៤, ២១/៥៤ និង ២២/៥៤ នៃអនុក្រឹត្យនេះ។

មាត្រា២១.-

សញ្ញាឋានៈអគ្គនាយករង ត្រូវបានកំណត់ ដូចខាងក្រោម÷

១. មួកកេពីនិងហ្ស៊ីកគី÷

មានក្បរក្បាច់រចនាពណ៌មាសដូចថ្នាក់អគ្គនាយក ខុសត្រង់ជាយក្បាំងខាងមុខក្បាច់ផ្កាឈូកបីស្រទាប់ ក្រួស្រូវ និងក្បាច់ភ្ញីទេស មានទំហំពីរភាគបីនៃថ្នាក់អគ្គនាយក។ ជាយក្បាំងខាងមុខ មានក្បាច់ខ្សែពួរពណ៌មាសពីរខ្សែទន្ទឹមគ្នាព័ទ្ធពីចុងម្ខាងដល់ចុងម្ខាង។

២. សក្តិស្មា÷

សក្តិស្មាមានក្បាច់រចនា និងពណ៌ដូចថ្នាក់អគ្គនាយក មានកងចក្រតំរៀបគ្នារាងត្រីកោណ បី។

សញ្ញាឋានៈអគ្គនាយករង មានគំរូ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ២៣/៥៤, ២៤/៥៤, ២៥/៥៤ និង ២៦/៥៤ នៃអនុក្រឹត្យនេះ។

មាត្រា២២.-

សញ្ញាឋានៈប្រធាននាយកដ្ឋាន និងប្រធានលេខាធិការដ្ឋាន ត្រូវបានកំណត់ ដូចខាងក្រោម÷

១. មួកកេពី និង ហ្ស៊ីកគី÷

មានក្បរក្បាច់រចនាដូចថ្នាក់អគ្គនាយក ខុសត្រង់ជាយក្បាំងខាងមុខក្បាច់ផ្កាឈូកបីស្រទាប់ ក្រួស្រូវ និងក្បាច់ភ្ញីទេសមានទំហំមួយភាគបីនៃថ្នាក់អគ្គនាយក។ ជាយក្បាំងខាងមុខមានក្បាច់ខ្សែពួរពណ៌មាសពីរខ្សែទន្ទឹមគ្នា ព័ទ្ធពីចុងម្ខាងដល់ចុងម្ខាង។

២. សក្តិស្មា÷

សក្តិស្មាមានក្បាច់រចនា និងពណ៌ដូចថ្នាក់អគ្គនាយក មានកងចក្រដាក់តំរៀបទន្ទឹមគ្នា ពីរ។

សញ្ញាឋានៈប្រធាននាយកដ្ឋាន និងប្រធានលេខាធិការដ្ឋាន មានគំរូ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ២៧/៥៤, ២៨/៥៤, ២៩/៥៤ និង ៣០/៥៤ នៃអនុក្រឹត្យនេះ។

មាត្រា២៣.-

សញ្ញាឋានៈអនុប្រធាននាយកដ្ឋាន អនុប្រធានលេខាធិការដ្ឋាន និងប្រធានសាខាគយនិងរដ្ឋាករ ត្រូវបានកំណត់ ដូចខាងក្រោម ÷

១. មកពីនិងហ្សែកគី÷

មានក្បួរក្បាច់រចនាដូចថ្នាក់ប្រធាននាយកដ្ឋាន និងថ្នាក់ប្រធានលេខាធិការដ្ឋាន តែគ្មានក្បាច់ខ្សែពួរពណ៌មាសពីរព័ទ្ធត្រង់ជាយក្បាំងខាងមុខ។

២. សក្តិស្មា÷

សក្តិស្មាមានក្បាច់រចនា និងពណ៌ដូចថ្នាក់អគ្គនាយក មានកងចក្រដាក់ចំកណ្តាលតែមួយ។

សញ្ញាឋានៈអនុប្រធាននាយកដ្ឋាន អនុប្រធានលេខាធិការដ្ឋាន និងប្រធានសាខាគយនិងរដ្ឋាករ មានគំរូ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ៣១/៥៤, ៣២/៥៤, ៣៣/៥៤ និង ៣៤/៥៤ នៃអនុក្រឹត្យនេះ។

មាត្រា២៤.-

សញ្ញាឋានៈប្រធានការិយាល័យ ជំនួយការនាយកដ្ឋាន អនុប្រធានសាខា និងប្រធានស្តីទីសាខាគយនិងរដ្ឋាករ ត្រូវបានកំណត់ ដូចខាងក្រោម ÷

១. មកពីនិងហ្សែកគី÷

មានក្បួរក្បាច់រចនាដូចថ្នាក់អគ្គនាយករង តែមានពណ៌ប្រាក់។

២. សក្តិស្មា÷

សក្តិស្មាមានក្បួរក្បាច់រចនា និងចំនួនកងចក្រ បី ដូចថ្នាក់អគ្គនាយករង តែមានពណ៌ប្រាក់។

សញ្ញាឋានៈប្រធានការិយាល័យ ជំនួយការនាយកដ្ឋាន អនុប្រធានសាខា និងប្រធានស្តីទីសាខាគយនិងរដ្ឋាករ មានគំរូ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ៣៥/៥៤, ៣៦/៥៤, ៣៧/៥៤ និង ៣៨/៥៤ នៃអនុក្រឹត្យនេះ។

មាត្រា២៥.-

សញ្ញាឋានៈអនុប្រធានការិយាល័យ ជំនួយការសាខា និងប្រធានស្តីទីការិយាល័យគយនិងរដ្ឋាករ ត្រូវបានកំណត់ ដូចខាងក្រោម ÷

១. មកពីនិងហ្សែកគី÷

មានក្បួរក្បាច់រចនាដូចថ្នាក់ប្រធាននាយកដ្ឋាន និងថ្នាក់ប្រធានលេខាធិការដ្ឋាន តែមានពណ៌ប្រាក់។

២. សក្តិស្មា÷

សក្តិស្មាមានក្បួរក្បាច់រចនា និងចំនួនកងចក្រពីរ ដូចថ្នាក់ប្រធាននាយកដ្ឋាន និងថ្នាក់ប្រធានលេខាធិការដ្ឋាន តែមានពណ៌ប្រាក់។

សញ្ញាសក្តិអនុប្រធានការិយាល័យ ជំនួយការសាខា និងប្រធានស្តីទីការិយាល័យគយនិងរដ្ឋាករ មានគំរូ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ៣៩/៥៤, ៤០/៥៤, ៤១/៥៤ និង ៤២/៥៤ នៃអនុក្រឹត្យនេះ។

មាត្រា២៦.-

សញ្ញាឋានៈភ្នាក់ងារគយនិងរដ្ឋាករ ត្រូវបានកំណត់ ដូចខាងក្រោម ÷

១. មកពីនិងហ្សែកគី÷

មានក្បួរក្បាច់រចនានិងពណ៌ប្រាក់ដូចថ្នាក់អនុប្រធានការិយាល័យ តែលើក្បាំងមុខគ្មានក្បាច់ផ្កាឈូកបីស្រទាប់ ក្បួរស្រូវ និងភ្ញីទេស។

២. សក្តិស្មា÷

សក្តិស្មាមានផ្នែកម្ខីពណ៌ខៀវលាត ផ្នែកខាងក្រោមមានចារឹកអក្សរមួល "**គយ និង រដ្ឋាករ**" លើបន្ទះលោហៈពណ៌ប្រាក់រាងប៉ូនជ្រុងទ្រវែង ផ្នែកខាងចុងមានរូបព្រះខ័នពីរឥតស្រោមដាក់ខ្វែងទ្រមកុដរាជ្យពណ៌ប្រាក់។ លើកំពូលមកុដរាជ្យមានកាំរស្មីរាងជារង្វង់ពណ៌ប្រាក់ ខាងលើកាំរស្មីមានឡេវ៉ូរូបព្រះសង្ខារពណ៌ប្រាក់សម្រាប់សក្តិស្មាស្រួចពាក់ជាមួយឯកសណ្ឋានប្រជុំឬសាហារីយ៉ែន និងឯកសណ្ឋានពិធីការ។ សក្តិស្មាកាត់ប្រើជាមួយឯកសណ្ឋានការងារ ខាងចុងគ្មានឡេវ៉ូរូបព្រះសង្ខារពណ៌ប្រាក់ទេ។

សញ្ញាឋានៈថ្នាក់ភ្នាក់ងារគយនិងរដ្ឋាករ ត្រូវកំណត់ដូចខាងក្រោម ÷

ក/ ថ្នាក់កម្មសិក្សាការី÷

លើសក្តិស្មា មានចារឹកអក្សរមួលថា "**កម្មសិក្សាការី**" នៅចន្លោះពាក្យថា "**គយ និង រដ្ឋាករ**" និងរូបព្រះខ័នឥតស្រោមដាក់ខ្វែងទ្រមកុដរាជ្យ។

ខ/ ថ្នាក់ភ្នាក់ងារគយនិងរដ្ឋាករបឋម÷

លើសក្តិស្មាមានសញ្ញាកងចក្រពណ៌ប្រាក់មួយគ្រាប់នៅចន្លោះពាក្យថា "**គយ និង រដ្ឋាករ**" និងរូបព្រះខ័នឥតស្រោមដាក់ខ្វែងទ្រមកុដរាជ្យ។

គ/ ថ្នាក់ភ្នាក់ងារគយនិងរដ្ឋាករជើមខ្សែ÷

លើសក្តិស្មាមានសញ្ញាកងចក្រពណ៌ប្រាក់ពីរគ្រាប់ដាក់តំរៀបទន្ទឹមគ្នានៅចន្លោះពាក្យថា "**គយ និង រដ្ឋាករ**" និងរូបព្រះខ័នឥតស្រោមដាក់ខ្វែងទ្រមកុដរាជ្យ។

ឃ/ ថ្នាក់ភ្នាក់ងារគយនិងរដ្ឋាករជើមខ្សែពិសេស÷

លើសក្តិស្មាមានសញ្ញាកងចក្រពណ៌ប្រាក់បីគ្រាប់ដាក់តំរៀបជារាងត្រីកោណនៅចន្លោះពាក្យថា "**គយ និង រដ្ឋាករ**" និងរូបព្រះខ័នឥតស្រោមដាក់ខ្វែងទ្រមកុដរាជ្យ។

ង/ ថ្នាក់ភ្នាក់ងារគយនិងរដ្ឋាករជើមខ្សែផុតថ្នាក់÷

សក្តិស្មាមានក្បួរក្បាច់រចនា និងពណ៌ប្រាក់ដូចថ្នាក់អនុប្រធានការិយាល័យ ជំនួយការសាខា និងប្រធានស្តីទីការិយាល័យគយនិងរដ្ឋាករ និងមានកងចក្រពណ៌ប្រាក់នៅចំកណ្តាលតែមួយ។

សញ្ញាសក្តិភ្នាក់ងារគយនិងរដ្ឋាករ មានគំរូ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ៣៩/៥៤, ៤០/៥៤, ៤១/៥៤ និង ៤២/៥៤ នៃអនុក្រឹត្យនេះ។

ជំពូកទី៥
ទោសប្បញ្ញត្តិ

មាត្រា២៧.-

មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវប្រើប្រាស់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈ ឱ្យបានត្រឹមត្រូវតាមការកំណត់ក្នុងអនុក្រឹត្យនេះ។

មន្ត្រីរាជការគយនិងរដ្ឋាករណាតែប្រែឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈ ឬប្រើប្រាស់ឯកសណ្ឋានមិនបានត្រឹមត្រូវ នឹងត្រូវទទួលទណ្ឌកម្មខាងវិន័យ ដោយអនុលោមតាមមាត្រា ៤០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការ

ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៦/ន.ស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤។

មាត្រា២៨.-

ជនណាមិនមែនជាមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជាប្រើប្រាស់ដោយគ្មានការអនុញ្ញាត ឬក្លែងបន្លំឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជា នឹងត្រូវផ្តន្ទាទោសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា២៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

១. ឯកសណ្ឋានការងារសម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ឧបសម្ព័ន្ធ ១/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ៣៤២អនក.ប.ក ចុះថ្ងៃទី២៧.... ខែ..ធ្នូ..... ឆ្នាំ២០១៤.

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



២. ឯកសណ្ឋានការងារសម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ឧបសម្ព័ន្ធ ២/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :៧៤២៧.ក.ប.ក ចុះថ្ងៃទី..២៣..ខែ...៩.....ឆ្នាំ២០១៤.

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៣. ឯកសណ្ឋានការងារសម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ឧបសម្ព័ន្ធ ៣/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ក ចុះថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ២០១៤

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៤. សញ្ញាឆន្ទៈជាតិរាជមូលដ្ឋានភ្ជាប់លើដើមដៃស្តាំអាវការងារ និងអាវសាហារីយ៉ង

ឧបសម្ព័ន្ធ ៤/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :នស/រកត/០១៤ ចុះថ្ងៃទី.៤.ខែ...ធ្នូ.....ឆ្នាំ.ជូ.ព.ស.២៥៥៨

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានអឺយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



៥. ឯកសណ្ឋានប្រចាំ សម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ឧបសម្ព័ន្ធ ៥/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :នស/រកត/ក ចុះថ្ងៃទី.ដ.ខ...ខែ...ធ្នូ.....ឆ្នាំ.ដ.ខ.ស

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៦. ឯកសណ្ឋានប្រចាំ "សាហារីយ៉ែន" សម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ឧបសម្ព័ន្ធ ៦/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :៣៤២..អនក្រ.បក ចុះថ្ងៃទី.២៣.... ខែ...ធ្នូ.....ឆ្នាំ.២.០១៤.

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



៧. ឯកសណ្ឋានពិធីការសម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ឧបសម្ព័ន្ធ ៧/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :...ក ចុះថ្ងៃទី...ខែ.....ឆ្នាំ.....

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៨. សម្លៀកបំពាក់ពិធីការសម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ឧបសម្ព័ន្ធ ៨/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :ណស.អនក្រ.ប ក ចុះថ្ងៃទី២៨...ខែ...ធ្នូ.....ឆ្នាំ២០១៤

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៩. ចែងឯកសណ្ឋានពិធីការសម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ឧបសម្ព័ន្ធ ៩/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :នស/រកត/០១១៤/០០ ក ចុះថ្ងៃទី២៣... ខែ...ធ្នូ.....ឆ្នាំ២០១៤

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១០. សញ្ញាសម្គាល់ខ្ចាស់លើកអាវសងខាងពណ៌មាសសម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានចំនាន:ចាប់ពីអនុប្រធាននាយកដ្ឋាន អនុប្រធានលេខាធិការដ្ឋាន និងប្រធានសាខាគយនិងរដ្ឋាករឡើង

ឧបសម្ព័ន្ធ ១០/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ចុះថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាចំនាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



(ទំហំខ្នាតរបស់សញ្ញាសម្គាល់ សោដាក់បញ្ឈរខ្វែងជាមួយយុថ្កាលើស្លាបសត្វត្រដាង ឯកភាពតែមួយគ្រប់ថ្នាក់)

១១. សញ្ញាគចក្រពាណិជ្ជសន្ធាស់លើហោះប៉ាវរាងស្តាំសម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានចំនាន:ចាប់ពីអនុប្រធាននាយកដ្ឋាន អនុប្រធានលេខាធិការដ្ឋាន និងប្រធានសាខាគយនិងរដ្ឋាករឡើង

ឧបសម្ព័ន្ធ ១១/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :ណស.អន្ត ២ ក ចុះថ្ងៃទី...ខែ.....ឆ្នាំ.....
ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាចំនាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

(ទំហំខ្នាតរបស់សញ្ញាសម្គាល់ កងចក្រ ឯកភាពតែមួយគ្រប់ថ្នាក់)

១២. ស្លាកឈ្មោះពណ៌មាសខ្នាស់ផ្លែកខាងលើហោចប៉ាអាចស្តាំសម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានប៉ាន:ចាប់ពីអនុប្រធាននាយកដ្ឋាន អនុប្រធានលេខាធិការដ្ឋាន និងប្រធានសាខាគយនិងរដ្ឋាករឡើង

ឧបសម្ព័ន្ធ ១២/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ...ក ចុះថ្ងៃទី...ខែ.....ឆ្នាំ.....
ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាប៉ាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



(ទំហំខ្នាតរបស់សញ្ញាសម្គាល់ ស្លាកឈ្មោះ ឯកភាពតែមួយគ្រប់ថ្នាក់)

១៣. ក្បាលខ្សែក្រវាត់ពណ៌មាសសម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានចាន:ចាប់ពី អនុប្រធាននាយកដ្ឋាន អនុប្រធានលេខាធិការដ្ឋាន និងប្រធានសាខាគយនិងរដ្ឋាករឡើង

ឧបសម្ព័ន្ធ ១៣/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ចុះថ្ងៃទី[illegible]...ខែ.....ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាចាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១៤. សញ្ញាសម្គាល់ខ្នាស់លើកអាវសខាងពណ៌ត្រាក់សម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានឋានៈចាប់ពីប្រធានការិយាល័យ ជំនួយការនាយកដ្ឋាន ប្រធានស្តីទីសាខា និងអនុប្រធានសាខាគយនិងរដ្ឋាករចុះ

ឧបសម្ព័ន្ធ ១៤/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ក ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១៥. សញ្ញាកងចក្រពាណិជ្ជាក់ខ្ពាស់លើហោះប៉ៅអាវស្តាំសម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានឋានៈចាប់ពីប្រធានការិយាល័យ ជំនួយការនាយកដ្ឋាន ប្រធានស្តីទីសាខា និងអនុប្រធានសាខាគយនិងរដ្ឋាករចុះ

ឧបសម្ព័ន្ធ ១៥/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :ណក.ករ.ចុះថ្ងៃទី..ខែ....ឆ្នាំ.....
ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

53

១៦. ស្លាកឈ្មោះពណ៌ប្រាក់ខ្មៅស៊ំផ្ទៃកខាងលើហោចប៉ៅអាចស្គាំសម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានឋានៈចាប់ពីប្រធានការិយាល័យ ជំនួយការនាយកដ្ឋាន ប្រធានស្តីទីសាខា និងអនុប្រធានសាខាគយនិងរដ្ឋាករចុះ

ឧបសម្ព័ន្ធ ១៦/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ [illegible] ក ចុះថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ[illegible]
ស្តីពី **ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

១៧. ស្លាកឈ្មោះពណ៌ក្រហក់ខ្លាស់ផ្លែកខាងលើហោះប៉ាអាចស្តាំសម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានចំនួន:ថ្លាក់កម្មសិក្សាការី

ឧបសម្ព័ន្ធ ១៧/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :...ចុះថ្ងៃទី...ខែ.....ឆ្នាំ.....

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាចំនួន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១៨. ក្បាលខ្សែក្រវាត់ពណ៌ប្រាក់សម្រាប់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានម៉ាន:ចាប់ពី ប្រធានការិយាល័យជំនួយការនាយកដ្ឋាន ប្រធានស្តីទីសាខា និងអនុប្រធានសាខាគយនិងរដ្ឋាករចុះ

ឧបសម្ព័ន្ធ ១៨/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ...ចុះថ្ងៃទី...ខែ.....ឆ្នាំ.....

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាម៉ាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១៩. ម្ហូបកេពីមានក្បាច់រចនាពណ៌ាមាសសម្រាប់ថ្នាក់អគ្គនាយក ពាក់ជាមួយឯកសណ្ឋានការងារ ឯកសណ្ឋានសាហារីយ៉ែន និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ១៩/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ...ក ចុះថ្ងៃទី...ខែ.....ឆ្នាំ.....

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាប័ន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



២០. មួកហ្វឹកកីមានក្បាច់រចនាពណ៌ាសសម្រាប់ថ្នាក់អគ្គនាយក ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ២០/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ [illegible] ចុះថ្ងៃទី[illegible]...ខែ...ធ្នូ.....ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២១. សក្តិស្មាស្រួចមានក្បាច់រចនាពណ៌មាសសម្រាប់ថ្នាក់អគ្គនាយក ពាក់ជាមួយឯកសណ្ឋានសាហារីយ៉ែន និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ២១/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ...... ចុះថ្ងៃទី..... ខែ..... ឆ្នាំ.....

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



(ទំហំខ្នាត សក្តិស្មាស្រួច ឯកភាពតែមួយគ្រប់ថ្នាក់)

២២. សក្តីស្នាកាត់ឯកសិទ្ធិពន្ធអាករសម្រាប់ទំនិញ: ថ្នាក់អគ្គនាយក ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ២២/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :.....ក ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



(ទំហំខ្នាត សក្តិស្នាកាត់ ឯកភាពតែមួយគ្រប់ថ្នាក់)

២៣. ម្ហូបកែពីមានក្បាច់រចនាពណ៌មាសសម្រាប់ថ្វាក់អគ្គនាយករង ពាក់ជាមួយឯកសណ្ឋានការងារ ឯកសណ្ឋានសាហារីយ៉ែន និងសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ២៣/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ [illegible] ចុះថ្ងៃទី[illegible]...ខែ.....ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាប័ន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២៤. មួកហ៊ីកគីមានក្បាច់រចនាពណ៌មាសសម្រាប់ថ្នាក់អគ្គនាយករង ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ២៤/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ចុះថ្ងៃទី[illegible]...ខែ.....ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២៥. សក្តិស្មាស្រួចមានក្បាច់រចនាពណ៌មាសសម្រាប់ថ្នាក់អគ្គនាយករង ពាក់ជាមួយឯកសណ្ឋានសាហារីយ៉ែន និង ឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ២៥/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ...ចុះថ្ងៃទី...ខែ...ឆ្នាំ...

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២៦. សក្តិស្នាការ៉ាមានក្បាច់រចនាពណ៌មាសសម្រាប់ថ្នាក់អគ្គនាយករង ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ២៦/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ...ក ចុះថ្ងៃទី...ខែ.....ឆ្នាំ...

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាប័ាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២៧. ម្ហូបកែពីមានក្បាច់រចនាពណ៌មាសសម្រាប់ថ្នាក់ប្រធាននាយកដ្ឋាន និងប្រធានលេខាធិការដ្ឋាន ពាក់ជាមួយឯកសណ្ឋានការងារ ឯកសណ្ឋានសាហារីយ៉ែន និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ២៧/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ក ចុះថ្ងៃទី[illegible]...ខែ.....ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២៨. ម្ជុលហ៊ុមកាំភ្លើងមានក្បាច់រចនាពណ៌មាសសម្រាប់ជាគ្រឿងប្រដាប់ប្រដានាយកដ្ឋាន និងប្រធានរដ្ឋបាលនាយកដ្ឋាន ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ២៨/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ [illegible] ចុះថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២៩. សក្តិស្មាស្មួចមានក្បាច់រចនាពណ៌មាសសម្រាប់ថ្នាក់ប្រធាននាយកដ្ឋាន និងប្រធានលេខាធិការដ្ឋាន ពាក់ជាមួយឯកសណ្ឋានសាមារីយ៉ែន និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ២៩/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ...ក ចុះថ្ងៃទី...ខែ.....ឆ្នាំ.....

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៣០. សក្តិស្នាក់មានក្បាច់រចនារាងពាមសម្រាប់ថ្នាក់ប្រធានគយកង្ហាន និងប្រធានរងខាងិកង្ហាន ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ៣០/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :ណស.អនុ.ក ចុះថ្ងៃទី២១... ខែ...ធ្នូ..... ឆ្នាំ២០១៤

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៣១. ឯកសណ្ឋានក្បាច់រចនារាណាំមាសសម្រាប់ថ្នាក់អនុប្រធាននាយកដ្ឋាន អនុប្រធានលេខាធិការដ្ឋាន និងប្រធានសាខាគយនិងរដ្ឋាករ ពាក់ជាមួយឯកសណ្ឋានការងារ ឯកសណ្ឋានសាហារីយ៉ែន និងសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ៣១/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



៣២. ម៉ូតហ៊ីប្រកាសីមានក្បាច់ចងភាជាប់មាសសម្រាប់ថ្នាក់អនុប្រធាននាយកដ្ឋាន អនុប្រធានលេខាធិការដ្ឋាន និង ប្រធានសាខាគយនិងរដ្ឋាករ ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ៣២/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៣៣. សក្តិស្មាស្រួចមានក្បាច់ចនរាងដាវសម្រាប់ថ្នាក់អនុប្រធាននាយកដ្ឋាន អនុប្រធានរងនាយកដ្ឋាន និង ប្រធានសាខាគយនិងរដ្ឋាករ ពាក់ជាមួយឯកសណ្ឋានសាហារីយ៉ែន និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ៣៣/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ក ចុះថ្ងៃទី[illegible]..... ខែ.....ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៣៥. សក្តិស្នាក់ងារក្បាច់ចនពាណិជ្ជសម្រាប់ថ្នាក់អនុប្រធាននាយកដ្ឋាន អនុប្រធានការិយាល័យនិងប្រធានសាខាគយនិងរដ្ឋាករ ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ៣៤/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ...ក ចុះថ្ងៃទី...ខែ...ឆ្នាំ...

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៣៥. ឃុកកេពីមានក្បាច់រចនាពណ៌ប្រាក់សម្រាប់ថ្នាក់ប្រធានការិយាល័យ ជំនួយការនាយកដ្ឋាន អនុប្រធានសាខា និងប្រធានស្តីទីសាខាគយនិងរដ្ឋាករ ពាក់ជាមួយឯកសណ្ឋានការងារ ឯកសណ្ឋានសាហាវ័យ និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ៣៥/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :ណស.អន្ត.ក្រ.ជក ចុះថ្ងៃទី...ខែ...ឆ្នាំ...

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៣៦. អូកហ៊ីរកគីមានក្បាច់រចនាពណ៌ឆ្លាក់សម្រាប់ថ្នាក់ប្រធានការិយាល័យ ជំនួយការនាយកដ្ឋាន អនុប្រធាន សាខា និងប្រធានស្តីទីសាខាគយនិងរដ្ឋាករ ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ៣៦/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :ណស.អនក្រ.ប ក ចុះថ្ងៃទី.៤.ខែ..ធ្នូ.....ឆ្នាំ២០១៩

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៣៧. សក្តិស្មាស្នួចមានក្បាច់រចនាពណ៌ប្រាក់សម្រាប់ជ្លាក់ប្រធានការិយាល័យ ជំនួយការនាយកដ្ឋាន អនុប្រធានសាខា និងប្រធានស្តីទីសាខាគយនិងរដ្ឋាករ ពាក់ជាមួយឯកសណ្ឋានសារពើយោធ និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ៣៧/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ...ក ចុះថ្ងៃទី...ខែ...ឆ្នាំ...

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៣៨. សក្តិស្នាការ៉ាងមានក្បាច់រចនាពណ៌ប្រាក់សម្រាប់ថ្នាក់ប្រធានការិយាល័យ ជំនួយការនាយកដ្ឋាន អនុប្រធានសាខា និងប្រធានស្តីទីសាខាគយនិងរដ្ឋាករ ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ៣៨/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ចុះថ្ងៃទី..[illegible]... ខែ.....[illegible]..... ឆ្នាំ[illegible].

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៣៩. ឃុកគេពីមានក្បាច់រចនាពណ៌ប្រាក់សម្រាប់ថ្ងាក់អនុប្រធានការិយាល័យ ជំនួយការសាខា និងប្រធានស្តីទីការិយាល័យគយនិងរដ្ឋាករ ពាក់ជាមួយឯកសណ្ឋានការងារ ឯកសណ្ឋានសាហារីយ៉ង និងឯកសណ្ឋានពិធីការ
ឧបសម្ព័ន្ធ ៣៩/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ចុះថ្ងៃទី[illegible]... ខែ.....ឆ្នូ..... ឆ្នាំ[illegible]
ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាប័ាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៤O. មួកហ៊ុមកីមានក្បាច់ចនាពណ៌ប្រាក់សម្រាប់ថ្នាក់អនុប្រធានការិយាល័យ ជំនួយការសាខា និងប្រធានស្តីទីការិយាល័យគយនិងរដ្ឋាករ ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ៤O/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ក ចុះថ្ងៃទី[illegible]....ខែ....[illegible].....ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៤១. សក្តិស្នាស្តួចមានក្បាច់រចនាពណ៌ប្រាក់សម្រាប់ ថ្នាក់អនុប្រធានការិយាល័យ ជំនួយការសាខា និងប្រធានស្តីទីការិយាល័យគយនិងរដ្ឋាករ ពាក់ជាមួយឯកសណ្ឋានសាហារីយ៉ែន និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ៤១/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :ណស.អនក្រ/ច ចុះថ្ងៃទី..... ខែ..... ឆ្នាំ.....

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៤២. សក្តិស្នាការ៉ាមានក្បាច់រចនាពណ៌ប្រាក់សម្រាប់ថ្នាក់អនុប្រធានការិយាល័យ ជំនួយការសាខា និងប្រធានស្តីទីការិយាល័យគយនិងរដ្ឋាករ ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ៤២/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ...ក ចុះថ្ងៃទី..ខែ.....ឆ្នាំ.....

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៤៣. មួកកេប៊ីមានក្បាច់ចនាពណ៌ប្រាក់សម្រាប់គ្រប់ថ្នាក់ឆ្មាគយនិងរដ្ឋាករ ពាក់ជាមួយ ឯកសណ្ឋានការងារ ឯកសណ្ឋានសាហាវ៉ែយ៉ង និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ៤៣/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ចុះថ្ងៃទី[illegible]....ខែ.....ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៤៤. មួកហ៊ីប្រកាមានក្បាច់ចនាពណ៌ប្រាក់សម្រាប់គ្រប់ថ្នាក់ស្នាក់ការគយនិងរដ្ឋាករ ពាក់ជាមួយ ឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ៤៨/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :ណស/រកត/០៨១៤/[illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៤៥. សក្តិស្នាស្មៀចមានក្បាច់រចនាពណ៌ប្រាក់សម្រាប់ថ្នាក់ត្រាក់ចារគយនិងរដ្ឋាករជើមខ្សែផ្តុតថ្នាក់ ពាក់ជាមួយឯកសណ្ឋានសាហារីយ៉ែន និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ៤៥/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ណ.ក.ប.ក.ក.ក

៤៦. សក្តិស្នាក់មានក្បាច់រចនាពណ៌ប្រាក់សម្រាប់ថ្នាក់ឆ្នាក់ចារគយនិងរដ្ឋាករដើមខ្សែផុតថ្នាក់ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ៤៦/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាចាំនៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៤៧. សក្តិស្មាស្មួចមានក្បាច់រចនាពណ៌ប្រាក់សម្រាប់ថ្នាក់ស្នាក់ងារគយនិងរដ្ឋាករដើមខ្សែពិសេសពាក់ជាមួយឯកសណ្ឋានសាហារីយ៉ែន និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ៤៧/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :ណស.អនក្រ/...ក ចុះថ្ងៃទី...ខែ.....ឆ្នាំ.....

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៤៨. សក្តិស្នាការ៉ាមានក្បាច់រចនាពណ៌ប្រាក់សម្រាប់ថ្នាក់ស្នាក់ការគយនិងរដ្ឋាករជើមខ្សែពិសេសពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ៤៨/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ [illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាចាន: របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៤៩. សក្តិស្មាស្រួចមានក្បាច់រចនាពណ៌ប្រាក់សម្រាប់ថ្នាក់ស្នាក់ការគយនិងរដ្ឋាករដើមខ្សែពាក់ជាមួយឯកសណ្ឋាន សាហារីយ៉ង និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ៤៩/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ចុះថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៥O. សក្តិស្លាកាត់មានក្បាច់រចនាពណ៌ក្រាក់សម្រាប់ថ្នាក់ឋានាក់ងារគយនិងរដ្ឋាករដើមខ្សែពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ៥O/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :ណស/រកត/[illegible] ចុះថ្ងៃទី..[illegible]..ខែ.....[illegible].....ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាចាំនាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៥១. សក្តិស្មាស្មួចមានក្បាច់រចនាពណ៌ឆ្លាក់សម្រាប់ថ្នាក់ស្តាក់ការគយនិងរដ្ឋាករបម្រមពាក់ជាមួយឯកសណ្ឋានសាហារីយ៉ែន និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ៥១/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាចាំនាន:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៥២. សក្តិស្នាការ៉ាត់មានក្បាច់រចនារាងសាំង្រាក់សម្រាប់ថ្នាក់ឆ្នាក់ចារគយនិងរដ្ឋាករបម៉ងពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ៥២/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ...ចុះថ្ងៃទី...ខែ...ឆ្នាំ...

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាចាំនង:របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៥៣. សក្តិស្នាស្មូចមានក្បាច់រចនារាងសិប្បាក់សម្រាប់ថ្នាក់កម្លាំងកងរាជអាវុធហត្ថ ពាក់ជាមួយឯកសណ្ឋានសាហារីយ៉ែន និងឯកសណ្ឋានពិធីការ

ឧបសម្ព័ន្ធ ៥៣/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ ...ចុះថ្ងៃទី...ខែ...ឆ្នាំ...

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាឋានៈរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៥៤. សក្តិស្នាការត់មានក្បាច់រចនាពណ៌ប្រាក់សម្រាប់ថ្នាក់កម្មសិក្សាការី ពាក់ជាមួយឯកសណ្ឋានការងារ

ឧបសម្ព័ន្ធ ៥៤/៥៤ ភ្ជាប់ជាមួយអនុក្រឹត្យលេខ :[illegible] ចុះថ្ងៃទី..[illegible]... ខែ.....[illegible]..... ឆ្នាំ[illegible]

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាចាំនាន: របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ